# I- ខុទ្ទកាល័យព្រះមហាក្សត្រ

## ១- ព្រះរាជក្រម

ព្រះរាជក្រមលេខលេខ ០៦.ន.ស.៩៤

យើង

ព្រះបាទសម្តេចព្រះនរោត្តម សីហនុ វរ្ម័ន

រាជហរិវង្ស ឧភតោសុជាត ពិសុទ្ធិពង្ស

អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសអោយប្រើនៅថ្ងៃទី ២៤-០៩-១៩៩៣
- បានទ្រង់យល់ព្រះរាជក្រឹត្យ ស្តីពីការតែងតាំងរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី ០១-១១-១៩៩៣
- គណៈរដ្ឋមន្ត្រីបានយល់ព្រមផង

### ប្រកាសអោយប្រើ

ច្បាប់ដែលបានអនុម័តដោយរដ្ឋសភា នាថ្ងៃទី ២១ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃ ព្រះរាជាណាចក្រកម្ពុជា ។

***

## ជំពូកទី ១

### បញ្ញត្តិទូទៅ

**មាត្រា ១ -**

អ្នករាជការគ្រប់ខ័ណ្ឌទាំងឡាយនៃព្រះរាជាណាចក្រកម្ពុជា ក្រៅពីអ្នករាជការដែលស្ថិតនៅក្នុងក្រុមតុលាការ និង ក្រុមនិតិបញ្ញត្តិដែលមានលក្ខណៈពិសេសនោះត្រូវស្ថិតនៅក្នុងសហលក្ខន្តិកៈនេះ ។

**មាត្រា ២ .-**

ច្បាប់នេះអនុវត្តចំពោះអ្នករាជការនៃព្រះរាជាណាចក្រកម្ពុជា ក្នុងក្របខ័ណ្ឌទាំងពួងដែលបាន បង្កើត និង រៀបចំ ឡើងតាមព្រះរាជក្រឹត្យ ហើយបានចូលធ្វើការនៅតាមក្រសួង ស្ថាប័ននានាដោយមានសិទ្ធិទទួលប្រាក់សោធននិវត្តន៍ ។

**មាត្រា ៣.-**

ក្របខ័ណ្ឌទាំងឡាយនៃអ្នករាជការត្រូវកំណត់ដោយលក្ខន្តិកៈដោយឡែកតាមព្រះរាជក្រឹត្យ ។

**មាត្រា ៤ .-**

ប្រភេទក្របខ័ណ្ឌ ឋានន្តរស័ក្តិ ថ្នាក់ សន្ទស្សន៍បៀវត្សអ្នករាជការក្នុងព្រះរាជាណាចក្រកម្ពុជា ព្រមទាំងលក្ខន្តិកៈដោយឡែកនៃអង្គផ្សេង ៗត្រូវកំណត់ដោយព្រះរាជក្រឹត្យ ។

**មាត្រា ៥ .-**

ការតែងតាំង ការតំលើងថ្នាក់ ការផ្លាស់ប្តូរ ការដាក់ក្រៅតំណែង ឬ ការដាក់អោយនៅក្រៅក្របខ័ណ្ឌ ត្រូវសំរេចដោយព្រះរាជក្រឹត្យ អនុក្រឹត្យ ឬ ប្រកាស ។

ការបញ្ឈប់លែងអោយធ្វើការដោយបង្ខំ ការដាក់អោយចូលនិវត្តន៍មុនកំណត់ និងការហួតងារនៃអ្នករាជការក្របខ័ណ្ឌ ត្រូវសំរេចតាមព្រះរាជក្រឹត្យ អនុក្រឹត្យ ឬប្រកាស ស្របតាមលក្ខន្តិកៈដោយឡែកនៃអ្នករាជការនេះ ។

**មាត្រា ៦ .-**

អ្នករាជការម្នាក់ ៗ មានសិទ្ធិសុំមើលកំណត់ត្រា និងឯកសារផ្សេងៗដែលជាសំណុំរឿងផ្ទាល់ខ្លួនមុននឹងត្រូវទទួលទណ្ឌកម្មខាងវិន័យ ឬមុននឹងត្រូវផ្លាស់ដោយបង្ខំ ។ សិទ្ធិដដែលនេះត្រូវបានអនុញ្ញាតអោយដល់អ្នករាជការណាដែលយឺតយូរមិនបានឡើងឋានន្តរស័ក្តិ ឬ ថ្នាក់តាមវេនអតីភាព ។

**មាត្រា ៧.-**

អ្នករាជការក្របខ័ណ្ឌអាចដាក់អោយទៅបំរើការ ឬបំពេញមុខងារក្រៅពីក្របខ័ណ្ឌដើមរបស់ខ្លួនបាន ក្នុងករណីចាំបាច់និងមានការយល់ព្រមពីសាមីខ្លួន ។

អ្នករាជការក្របខ័ណ្ឌមានសិទ្ធិសុំផ្លាស់កន្លែងធ្វើការទៅតាមប្តី ឬប្រពន្ធបាន ។

**មាត្រា ៨ ..**

នៅក្នុងក្របខ័ណ្ឌនីមួយ ៗ តាមគោលការណ៍ អ្នករាជការក្នុងឋានន្តរស័ក្តិ ឬថ្នាក់ណាមួយមិនអាចចាត់អោយទៅធ្វើការក្រោមបង្គាប់អ្នករាជការម្នាក់ទៀតដែលមានឋានន្តរស័ក្តិ ឬថ្នាក់ទាបជាងខ្លួនទេ លើកលើងតែក្នុងករណីចាំបាច់ហើយសាមីខ្លួនដែលមានឋានន្តរស័ក្តិ ឬថ្នាក់ធំជាងនោះយល់ព្រម ។

**មាត្រា ៩ ..**

របបស្តីពីការសុំច្បាប់ និងការឈប់សំរាកប្រចាំឆ្នាំ ប្រាក់បំណាច់បេសកកម្ម ប្រាក់បំណាច់ព្យាបាលរោគក្នុងមន្ទីរពេទ្យ និងប្រាក់សោធននិវត្តន៍ ។ល។ ត្រូវកំណត់តាមច្បាប់ដោយឡែក ។

**មាត្រា ១០ ..**

បៀវត្សនិងប្រាក់បន្ថាប់បន្សំនៃបៀវត្ស ដូចជាប្រាក់បំណាច់បន្ថែមនិងប្រាក់បំណាច់ទទួលខុសត្រូវ ប្រាក់តំបន់ ប្រាក់ឧបត្ថម្ភកូននិងប្រពន្ធ ប្រាក់ថ្លៃឈ្នួលផ្ទះ ថ្លៃសង្ហារឹមក្នុងផ្ទះ ថ្លៃជាវមធ្យោបាយការងារ ថ្លៃទឹក និង ថ្លៃភ្លើង ។ល។ នៃអ្នករាជការត្រូវកំណត់តាមច្បាប់ដោយឡែក ។

## ជំពូកទី ២

## ការជ្រើសរើសអោយចូលធ្វើការ

**មាត្រា ១១ ..**

បេក្ខជនទាំងពីរភេទអាចទទួលអោយចូលធ្វើការក្នុងក្របខ័ណ្ឌរាជការបាន លុះត្រាតែបេក្ខជននោះបានបំពេញនូវលក្ខខ័ណ្ឌដូចខាងក្រោម ÷

១_ មានសញ្ជាតិជាខ្មែរ ។

២_ មានអាយុយ៉ាងតិច ១៨ ឆ្នាំ ហើយមិនលើសពី ២៥ ឆ្នាំ ប៉ុន្តែមានករណីលើកលែងខះដូចមានចែងខាងក្រោមនេះ ÷

ក_ ចំពោះបេក្ខជនដែលមានសញ្ញាប័ត្រឧត្តមសិក្សា ការកំរិតអាយុ ត្រូវបានរំកិលពី ២៥ ឆ្នាំ ដល់ ៣០ ឆ្នាំ យ៉ាងច្រើនបំផុត ។

ខ_ ចំពោះបេក្ខជនដែលបានរៀននៅគ្រឹះស្ថានឧត្តមសិក្សា មួយឆ្នាំ ឬច្រើនឆ្នាំ ហើយមិនបានសញ្ញាប័ត្រនោះ ការកំរិតអាយុ ២៥ ឆ្នាំ នឹងត្រូវរំកិលតាមចំនួនឆ្នាំដែលបានរៀនក្នុងគ្រឹះស្ថានឧត្តមសិក្សាទាំងនោះ តែមិនអោយលើសពីអាយុ ៣០ ឆ្នាំ ។

គ_ ចំពោះបេក្ខជនដែលបានបំពេញកាតព្វកិច្ចយោធា ការកំរិតអាយុត្រូវរំកិលតាមចំនួនឆ្នាំដែលបានបំពេញកាតព្វកិច្ចយោធានោះ ។

ឃ_ ក្នុងពេលចាំបាច់ រាជរដ្ឋាភិបាលអាចចេញអនុក្រឹត្យលើកលែងការកំណត់អាយុនៃបេក្ខជន ដើម្បី បំពេញសេចក្តីត្រូវការជាអាទិភាព និងដើម្បីផលប្រយោជន៍ជាតិ ។

៣_ មិនបានប្រាសចាកសិទ្ធិខាងផ្លូវរដ្ឋប្បវេណី សិទ្ធិជាពលរដ្ឋ សិទ្ធិខាងនយោបាយ ។

៤_ មិនដែលមានទោសឧក្រិដ្ឋ ឬមជ្ឈិមពីរឿងល្មើសប៉ះពាល់ដល់ទំនៀមទំលាប់ កិត្តិយសនិងភាពសុចរិត ។

៥_ ត្រូវមានកាយសម្បទាគ្រប់គ្រាន់ក្នុងការបំពេញការងារដែលលក្ខណៈសម្បត្តិមានចែងទុកជាមុន នៅក្នុងសេចក្តីណែនាំ និងបទបញ្ជាជាធរមាន ។

៦_ បងប្អូនជនជាតិភាគតិច បងប្អូននៅតំបន់ដាច់ស្រយាល និង បងប្អូននារីភេទអាចត្រូវបានផ្តល់អាទិភាព និងភាពងាយស្រួល ។

៧_ ត្រូវបំពេញលក្ខខ័ណ្ឌខាងសមត្ថភាពគ្រប់គ្រាន់ ដូចមានចែងក្នុងបទបញ្ជាដោយឡែក នៃអង្គដែលខ្លួនមានបំណងសុំចូលបំរើការងារ ។

## មាត្រា ១២ ._

លក្ខខ័ណ្ឌស្តីពីសញ្ជាតិ និងអាយុត្រូវបញ្ជាក់តាមសំបុត្រអត្រាក្លូលដ្ឋាន ឬតាមសាលក្រមជំនួសអត្រានុក្លូលដ្ឋាននោះ ។

សេចក្តីបញ្ជាក់ថា គ្មានទោសត្រូវកំណត់ក្នុងសំបុត្រថ្កោលទោសមួយមានសុពលភាព ៣ ខែ ដែលចេញ អោយដោយក្រសួងយុត្តិធម៌ ។

## មាត្រា ១៣ ._

ជាគោលការណ៍ រាល់ការជ្រើសរើសបេក្ខជនអោយចូលក្នុងក្របខ័ណ្ឌ ត្រូវធ្វើឡើងតាមការប្រឡងប្រជែង លើកលែងតែមានការកំណត់ផ្សេងពីនេះដោយរាជរដ្ឋាភិបាល ។

## មាត្រា ១៤ ._

កាលបរិច្ឆេទនៃការប្រឡងប្រជែងជ្រើសរើសអោយចូលក្នុងក្របខ័ណ្ឌរាជការ ត្រូវកំណត់ និងផ្សព្វផ្សាយយ៉ាងតិច ៣ ខែ មុនថ្ងៃដែលបើកអោយចូលប្រឡង ។ ក្នុងករណីដែលមានប្រញាប់ការផ្សព្វផ្សាយត្រូវធ្វើយ៉ាង

**មាត្រា ១៥ ៈ**

ជាគោលការណ៍ រាល់ការប្រឡងប្រជែងជ្រើសរើសអោយចូលក្របខ័ណ្ឌរាជការ ត្រូវមានតំណាងស្ថាប័នមុខងារសាធារណៈចូលរួម ។

# ជំពូកទី ៣
## ការធ្វើកម្មសិក្សា ការតាំងស៊ប់ក្នុងក្របខ័ណ្ឌ ការបញ្ចេញពីក្របខ័ណ្ឌ

**មាត្រា ១៦ ៈ**

ការតាំងស៊ប់ក្នុងក្របខ័ណ្ឌរាជការនិងអាចសំរេចបានជាស្ថាពរ ក្រោយពីបានធ្វើកម្មសិក្សាសាកល្បងមួយ ។ ផ្ទុយទៅវិញ អាចលើកលែងមិនបាច់ធ្វើកម្មសិក្សា ចំពោះបេក្ខជនទាំងឡាយដែលបានប្រឡងជាប់ទៅកាន់ប្រភេទក្របខ័ណ្ឌខ្ពស់ជាង នៃអង្គដែលខ្លួនធ្លាប់ជាមន្ត្រី រាជការចាស់តាំងស៊ប់ក្នុងក្របខ័ណ្ឌម្តងរួចហើយ ។

**មាត្រា ១៧ ៈ**

បៀវត្សរបស់កម្មសិក្សាការីត្រូវកាត់ទុកប្រាក់សម្រាប់សោធននិវត្តន៍ ។ បើសិនជាកម្មសិក្សាការីនោះមិនបានតាំងស៊ប់ក្នុងក្របខ័ណ្ឌរាជការទេនោះ ប្រាក់ដែលបានកាត់ទុកសម្រាប់សោធននិវត្តន៍នេះត្រូវសងមកសាមីខ្លួនវិញ ។

**មាត្រា ១៨ ៈ**

រយៈពេលកម្មសិក្សាត្រូវកំរិត ១២ ខែ។រយៈពេលកម្មសិក្សាត្រូវគិតពីថ្ងៃតែងតាំងកម្មសិក្សាការីនោះ ។ កម្មសិក្សានេះមិនត្រូវយកជាការបានទេ បើកាលណាសាមីជនអាក់ខានមកធ្វើកម្មសិក្សាសរុបលើសពី ៣០ ថ្ងៃ ។ ក្នុងករណីនេះ សាមីជនត្រូវបន្តធ្វើកម្មសិក្សានៅឆ្នាំទី ២ ទៀត ។

- ការតាំងស៊ប់ក្នុងក្របខ័ណ្ឌរាជការនឹងធ្វើទៅបានលុះត្រាតែ កម្មសិក្សាការីបានបំពេញ កម្មសិក្សាចំនួន ១២ ខែ ជាពិតប្រាកដ ។ រយៈពេលកម្មសិក្សានេះត្រូវបន្ថយ ៦ ខែ ចំពោះមន្ត្រីរាជការក្របខ័ណ្ឌចាស់ដែលបាន ប្រឡងជាប់ចូល ក្របខ័ណ្ឌថ្មីមួយទៀតដោយរក្សាអតីតភាពដែលមានពីមុន ។
- ការតាំងស៊ប់ក្នុងក្របខ័ណ្ឌត្រូវធ្វើឡើងដោយអាជ្ញាធរមានសមត្ថកិច្ចតែងតាំង តាមសំណើពីប្រធានអង្គភាព ។ ការតែងតាំងស៊ប់នៃកម្មសិក្សាការីត្រូវតែមានការរួមយោបល់ពីគណៈកម្មការមួយ ។

## សមាសភាពគណៈកម្មការនេះមាន

១_ ប្រធានស្ថាប័ន ឬ តំណាង ប្រធាន

២_ ប្រធានអង្គភាពដែលគ្រប់គ្រង ឬ តំណាង សមាជិក

៣_ ប្រធានការិយាល័យបុគ្គលិក ឬ តំណាង សមាជិក

៤_ អ្នករាជការមួយរូបដែលមានក្របខ័ណ្ឌជាមួយគ្នា សមាជិក

កម្មសិក្សាការីណាដែលមិនបានបង្ហាញអោយឃើញថា ខ្លួនមានសម្បទាវិជ្ជាជីវៈគ្រប់គ្រាន់ ឬក៏ពិនិត្យឃើញថារបៀបធ្វើការងារមានការខ្ជីខ្ជា ឬក៏គ្មានកំលាំងពលំនឹងកាន់មុខតំណែងបាន តាមលក្ខខ័ណ្ឌដែលបានកំណត់ក្នុងសេចក្តីណែនាំជាធរមាន អាចបញ្ឈប់មិនអោយធ្វើការនេះពេលណាក៏បានក្នុងរយៈពេលកម្មសិក្សា ។ ត្រូវបញ្ឈប់មិនអោយធ្វើការដូចគ្នាដែរ ចំពោះអ្នករាជការណាដែលបានប្រព្រឹត្តិបទល្មើសនឹងមាត្រា ៣៣ និងមាត្រាបន្តបន្ទាប់ទៅមុខទៀតនៃច្បាប់នេះ ដែលចែងពីការដាក់វិន័យចំពោះមន្ត្រីរាជការ ។

ការបញ្ឈប់មិនអោយធ្វើការ ឬ ការតាំងស៊ប់ក្នុងក្របខ័ណ្ឌ តោងតែសំរេចជាដាច់ខាតក្នុងរយៈពេល ៣ ខែ ក្រោយថ្ងៃផុតកំណត់រយៈពេលកម្មសិក្សា ១២ ខែ កន្លងមក ។ ការតែងតាំងស៊ប់ក្នុងក្របខ័ណ្ឌចាប់ផ្តើមមានប្រសិទ្ធភាព ក្នុងផ្នែកបៀវត្សក៏ដូចជាអតីតភាពការងារសម្រាប់ឡើងឋានន្តរសក្តិ ឬថ្នាក់ ចាប់ពីថ្ងៃផុតកំណត់នៃកម្មសិក្សានេះ។ ប៉ុន្តែអតីតភាពការងារសំរាប់ចូលនិវត្តន៍ត្រូវបានគិតបញ្ចូល តាំងពីថ្ងៃចាប់ផ្តើមធ្វើកម្មសិក្សា ។

### មាត្រា ១៩ _

អ្នករាជការណាដែលធ្វើការតទៅទៀតមិនបាន ដោយហេតុមកពីបាត់បង់សម្បទាវិជ្ជាជីវៈ ហើយដែលមិនបាន បំពេញលក្ខណ៍គ្រប់គ្រាន់ដើម្បីទទួលសោធននិវត្តន៍អាចនឹងត្រូវបញ្ឈប់មិនអោយ ធ្វើការតទៅទៀតនៅពេលណាក៏បាន ។

អ្នករាជការមានអតីតភាពការងារចាប់ពី ២០ ឆ្នាំឡើងទៅ ដែលតម្រូវអោយចូលនិវត្តន៍ដោយបាត់បង់សម្បទា វិជ្ជាជីវៈ មានសិទ្ធិទទួលសោធនសមាមាត្រ ។ បើអតីតភាពការងារក្រោម ២០ ឆ្នាំ អ្នករាជការដែលបាត់បង់សម្បទាវិជ្ជា ជីវៈមានសិទ្ធិទទួលប្រាក់សោធនដែលបានកាត់ទុក និងប្រាក់ឧបត្ថម្ភផ្សេងៗរបស់រដ្ឋតែមួយលើក ។

ការកំណត់ថាបាត់បង់សម្បទាវិជ្ជាជីវៈ ត្រូវសំរេចដោយគណៈកម្មការមួយដែលមាន សមាសភាពដូចខាងក្រោមនេះ :

១_ ប្រធានស្ថាប័នឬតំណាង ប្រធាន

២_ ប្រធានអង្គភាពដែលគ្រប់គ្រង ឬតំណាង សមាជិក

៣- ប្រធានការិយាល័យបុគ្គលិក ឬតំណាង សមាជិក

៤- គ្រូពេទ្យដែលបានទទួលសច្ចាប្រណិធាន ហើយដែលចាត់តាំងឡើងដោយក្រសួងសុខាភិបាល សមាជិក

៥- អ្នករាជការដែលនៅក្នុងក្របខ័ណ្ឌជាមួយគ្នាពីរនាក់ដែលមានឋានន្តរស័ក្តិយ៉ាងហោចណាស់ស្មើនឹងសាមីខ្លួន សមាជិក

## ជំពូកទី៤

## ការឡើងឋានន្តរស័ក្តិ ឬឡើងថ្នាក់

**មាត្រា ២០ .-**

ការឡើងឋានន្តរស័ក្តិ ឬឡើងថ្នាក់នៃអ្នករាជការត្រូវធ្វើតាមវេនជ្រើសរើសក៏បាន ឬ តាមវេនជ្រើសរើស និងអតីតភាពជាមួយគ្នាក៏បាន ។

តាមធម្មតា រយៈពេលអប្បបរមានៃការឡើងថ្នាក់ត្រូវកំរិត ២ ឆ្នាំ ។ ដើម្បីនឹងអាចអោយឡើងថ្នាក់តាមការជ្រើសរើសយកនោះ ត្រូវមានចុះឈ្មោះក្នុងតារាងឡើងថ្នាក់ ។ ក្នុងករណីអ្នករាជការណាម្នាក់បំពេញការងារមានស្នាដៃល្អពិសេស ត្រូវបានតំលើងថ្នាក់ជាស្វ័យប្រវត្តិដោយពុំគិតពីលក្ខខ័ណ្ឌអតីតភាពឡើយ ។

ចំពោះក្របខ័ណ្ឌទាំងអស់ ការតំលើងថ្នាក់ត្រូវមានការយល់ព្រមពីស្ថាប័នមានសមត្ថកិច្ចក្នុងការតែងតាំងដែល សំរេចអោយតាមកំរិតនៃកន្លែងទំនេរក្នុងឋានន្តរស័ក្តិនីមួយ ៗ និងតាមកំរិតមុខចំណាយថវិកា ។

**មាត្រា ២១ .-**

អ្នករាជកាក្នុងឋានន្តរសក្តិតែមួយអាចឡើងថ្នាក់បានម្តងមួយថ្នាក់ បើដូរឋានន្តរស័ក្តិ ត្រូវឡើងទៅថ្នាក់ ក្រោមបំផុតនៃស័ក្តិខ្ពស់ជាងនោះ ។ នៅពេលដែលអ្នករាជការត្រូវផ្លាស់ប្តូរប្រភេទក្រមខ័ណ្ឌ ដោយសារបានប្រឡងជាប់ទៅប្រភេទក្របខ័ណ្ឌខ្ពស់ សន្ទស្សន៍បៀវត្សត្រូវគិតត្រឹមថ្នាក់ដែលមានកំរិតស្មើ ឬខ្ពស់បន្ទាប់ពីសន្ទស្សន៍បៀវត្សចាស់នៃអ្នករាជការនោះ ។

ការតំលើងឋានន្តរស័ក្តិ ឬថ្នាក់ទាំងឡាយ ត្រូវគិតលើផ្នែកបៀវត្សនិងអតីតភាពចាប់ពីកាលបរិច្ឆេទដែលការតំលើងឋានន្តរស័ក្តិនេះត្រូវបានប្រកាស ។

**មាត្រា ២២ ..**

ជារៀងរាល់ឆ្នាំ នៅខែ មករា អ្នករាជការទាំងអស់ដែលមានសិទ្ធិត្រូវតំលើងឋានន្តរសក្តិ ឬថ្នាក់ ត្រូវបំពេញព្រឹត្តិប័ត្រ ពិន្ទុសម្រាប់តំលើងថ្នាក់របស់ខ្លួន ។ ព្រឹត្តិប័ត្រពិន្ទុនេះត្រូវបានប្រធានអង្គភាពធ្វើការកត់សម្គាល់ និងបញ្ជាក់បន្ថែមព្រមទាំងកំណត់ជាពិន្ទុ ។

អភិបាលខេត្ត ក្រុង មានភារៈផ្តល់យោបល់ទៅលើកិរិយាមាយាទ ការគោរពវិន័យសាមគ្គីភាពរបស់ប្រធានមន្ទីរនានានៅខេត្ត ក្រុង ។

តារាងពិន្ទុទាំងនោះត្រូវបញ្ជូនតាមលិខិតសំងាត់ទៅប្រធានស្ថាប័នសាមី ។

**មាត្រា ២៣ ..**

ក្រោយពីបានចារលើព្រឹត្តិប័ត្រពិន្ទុ តាមក្របខ័ណ្ឌ និងលំដាប់លំដោយអតីតភាព ប្រធានអង្គភាព ឬប្រធានស្ថាប័នមាន សមត្ថកិច្ចបញ្ឈប់បញ្ជីស្នើសុំឡើងថ្នាក់នោះ ។

បញ្ជីខាងលើនេះ ត្រូវចុះឈ្មោះអ្នករាជការដែលបានបំពេញលក្ខខ័ណ្ឌដូចខាងក្រោម ÷

១_ តាមធម្មតា អតីតភាពការងារយ៉ាងតិចបាន ២ ឆ្នាំ ចំពោះឋានន្តរស័ក្តិ ឬ ថ្នាក់ដែលបានទទួលគិតចាប់ពីថ្ងៃចូល ឆ្នាំខ្មែរដែលជាថ្ងៃធ្វើតារាងឡើងថ្នាក់ ។

២_ ត្រូវមានសេចក្តីស្នើសុំអោយឡើងថ្នាក់ត្រឹមត្រូវតាមច្បាប់ ពីថ្នាក់គ្រប់គ្រងបន្តបន្ទាប់ដែលសាមីខ្លួននៅក្រោមបង្គាប់ ។

**មាត្រា ២៤ ..**

ព្រឹត្តិប័ត្រកំណត់ពិន្ទុវិជ្ជាជីវៈ និងស្ថានភាពសេវាកម្មនៃរាជការម្នាក់ ១ ដែលស្នើសុំឡើងឋានន្តរស័ក្តិ ឬថ្នាក់ ត្រូវដាក់ អោយគណៈកម្មការចំណាត់ថ្នាក់ពិនិត្យ ។

**មាត្រា ២៥ ..**

តារាងតំលើងឋានន្តរស័ក្តិ ឬថ្នាក់ ត្រូវធ្វើដោយគណៈកម្មាការចំណាត់ថ្នាក់តែងតាំងតាមសំណើប្រធានអង្គភាព ឬពីប្រធានស្ថាប័នសាមី ។

គណៈកម្មការនេះ ត្រូវតែងតាំងឡើងតាមព្រះរាជក្រឹត្យ អនុក្រឹត្យ ឬ តាមប្រកាសក្រសួង ហើយត្រូវមានសមាសភាព ដូចតទៅ :

| | |
|---|---|
| ១_ ប្រធានស្ថាប័ន ឬ តំណាង | ប្រធាន |
| ២_ ប្រធានអង្គភាពដែលគ្រប់គ្រង ឬតំណាង | សមាជិក |

៣- ប្រធានការិយាល័យបុគ្គលិក ឬ តំណាង សមាជិក

៤- អ្នករាជការពីរនាក់ ដែលនៅក្នុងក្របខ័ណ្ឌជាមួយគ្នា តែមានឋានន្តរស័ក្តិ និងថ្នាក់ខ្ពស់ជាង ឬបើគ្មានទេ ត្រូវយកអ្នករាជការក្នុងក្របខ័ណ្ឌឯទៀតក៏បានដែរ ។ អ្នករាជការទាំងនេះ ត្រូវជ្រើសរើសឡើងដោយការបោះឆ្នោត សមាជិក ។

**មាត្រា ២៦ .-**

តារាងតម្លើងឋានន្តរស័ក្តិ ឬថ្នាក់ ត្រូវធ្វើឡើងក្នុងត្រីមាសទី៤នៃឆ្នាំនីមួយៗ (ត្រីមាសទី៤នៃឆ្នាំខ្មែរ) ។ តារាងនេះ ប្រើការសំរាប់ឆ្នាំបន្ទាប់ និងមានតែឈ្មោះអ្នកដែលស្នើឡើងតាមវេនជ្រើសរើស ។

គណៈកម្មការចំណាត់ថ្នាក់ប្រជុំពេញអង្គ កំណត់មធ្យមភាគនៃពិន្ទុចំពោះបេក្ខជនម្នាក់ៗ ពីពិន្ទុ ០ ដល់ពិន្ទុ ២០ រួច គណៈកម្មការនេះស្រង់ឈ្មោះបេក្ខជនតាមលំដាប់លំដោយពិន្ទុ ។

ការចុះឈ្មោះក្នុងតារាងតម្លើងឋានន្តរស័ក្តិឬថ្នាក់ ត្រូវធ្វើតាមចំនួនកន្លែងដែលមានសល់ទំនេរ ។

ចំនួនឈ្មោះដែលចុះក្នុងតារាងតម្លើងឋានន្តរស័ក្តិ ឬថ្នាក់ប្រចាំឆ្នាំសំរាប់ក្របខ័ណ្ឌនីមួយៗ នៅក្នុងឋានន្តរស័ក្តិ ឬ ថ្នាក់នីមួយៗ ត្រូវកំណត់ដោយព្រះរាជក្រឹត្យ អនុក្រឹត្យ ឬប្រកាសតាមចំនួនកន្លែងទំនេរ និងតាមមុខចំណាយដែលមាន គ្រោងទុកក្នុងថវិកា ។

**មាត្រា ២៧ .-**

ក្នុងករណីដែលមិនអាចចុះឈ្មោះបេក្ខជនទាំងអស់ក្នុងតារាងតម្លើងឋានន្តរស័ក្តិ ឬ ថ្នាក់នៃឆ្នាំនេះបានទេ សាមីជន ត្រូវមានសិទ្ធិចុះឈ្មោះមុនគេបង្អស់តាមលេខរៀង ក្នុងតារាងតម្លើងឋានន្តរស័ក្តិ ឬថ្នាក់ ឆ្នាំបន្ទាប់មកទៀត លើកលែងតែគណៈកម្មការសំរេចផ្ទុយពីនេះ ដោយមានសេចក្តីរាយការណ៍សមហេតុផលពីប្រធានគ្រប់គ្រងសាមី ។

**មាត្រា ២៨ .-**

ដើម្បីចុះឈ្មោះក្នុងតារាងឡើងឋានន្តរស័ក្តិ ឬថ្នាក់បាននៅថ្ងៃ ១៣ ខែ មេសា ក្នុងឆ្នាំ នីមួយៗ បេក្ខជនត្រូវមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ដែលមានចែងក្នុងលក្ខន្តិកៈ ដោយឡែកនៃអង្គរបស់ខ្លួនដើម្បីឡើងថ្នាក់ ។ ក្នុងករណីពិសេស គណៈកម្មការចំណាត់ថ្នាក់មានសិទ្ធិចុះឈ្មោះក្នុងតារាងតម្លើងឋានន្តរស័ក្តិ ឬថ្នាក់បាននូវអ្នករាជការណាដែលអង្គ ភាពគ្រប់គ្រងមិនបានស្នើសុំតម្លើងឋានន្តរស័ក្តិ ឬថ្នាក់ ។

**មាត្រា ២៩ .-**

អតីតភាពការងារមន្ត្រី រាជការដែលធ្វើការនៅតំបន់ឆ្ងាយដាច់ស្រយាល តំបន់ប៉ះពាល់សុខភាព ឬគ្រោះថ្នាក់ ត្រូវគិតបន្ថែមពាក់កណ្តាលនៃអតីតភាពនេះទៀត ក្នុងការចុះឈ្មោះលើតារាងរាយនាមសំរាប់ស្នើសុំតម្លើងឋានន្តរស័ក្តិឬថ្នាក់ ។

**មាត្រា ៣០ .-**

ការតម្លើងឋានន្តរស័ក្តិឬថ្នាក់តាមវេនអតីតភាព ត្រូវឆ្លាស់គ្នាជាមួយការឡើងឋានន្តរ ស័ក្តិឬថ្នាក់តាមវេនជ្រើសរើសទៅតាមសមាមាត្រដែលបានគ្រោងទុកក្នុងលក្ខន្តិកៈដោយឡែកសំរាប់អង្គនីមួយៗ ។

ការឡើងឋានន្តរស័ក្តិឬថ្នាក់តាមវេនអតីតភាព ត្រូវសំរេចតាមលំដាប់លំដោយអតីតភាព ជាដាច់ខាតក្នុងបញ្ជីរាយនាមអ្នករាជការដែលត្រូវសុំអោយឡើងឋានន្តរស័ក្តិ ឬថ្នាក់នោះ ។

**មាត្រា ៣១ .-**

សិទ្ធិត្រូវបានឡើងឋានន្តរស័ក្តិឬថ្នាក់ ដោយវេនជ្រើសរើស ក៏ដូចជាដោយវេនអតីតភាព ត្រូវផ្អាកចំពោះអ្នករាជការ ណាដែលជាប់ចោទជាបទវិន័យឬជាបទតុលាការ ។

**មាត្រា ៣២ .-**

ឋានន្តរស័ក្តិកិត្តិយស អាចផ្តល់ដោយអាជ្ញាធរមានសមត្ថកិច្ចតែងតាំងជូនមន្ត្រីរាជការចូលនិវត្តន៍ ឬលា លែង ឬដែលបាន ដាក់អោយឈប់ធ្វើការងារដោយបាត់បង់សមត្ថភាពការងារ ។

ឋានន្តរស័ក្តិកិត្តិយសជាកិច្ចបច្ឆាមរណៈអាចផ្តល់ជូនមន្ត្រី រាជការដែលបានទទួលមរណភាព ។

# ជំពូកទី ៥

## វិន័យ

**មាត្រា ៣៣ .-**

អ្នករាជការគ្រប់រូប ត្រូវតែគោរពអនុវត្តច្បាប់និងបទបញ្ជា ហើយនិងការណែនាំថ្នាក់លើរបស់ខ្លួនៗ

អ្នករាជការត្រូវទទួលខុសត្រូវចំពោះមុខថ្នាក់លើអំពីកិច្ចការរបស់ខ្លួន និងអំពើដែលអាចធ្វើឱ្យប៉ះពាល់ទៅលើ សេចក្តីថ្លៃថ្នូរនិងកិត្តិយសរបស់ខ្លួន ។

អ្នករាជការក្នុងក្របខ័ណ្ឌទាំងអស់ ត្រូវតែគោរពបញ្ជាថ្នាក់លើដែលបានចាត់ឱ្យទៅបំរើការងារទោះបីទីតំបន់ណាក៏ដោយ ទាំងក្នុងនិងក្រៅប្រទេស ។

**មាត្រា ៣៤.-**

អ្នករាជការទាំងឡាយមិនអាចឈប់ធ្វើការ ដោយគ្មានបានទទួលការអនុញ្ញាតជាមុនពីថ្នាក់លើរបស់ខ្លួន ឬដោយគ្មានមូលហេតុត្រឹមត្រូវ។ការឈប់ធ្វើការ ឬការខានទៅធ្វើការដោយគ្មានការអនុញ្ញាតឬដោយគ្មាន មូលហេតុត្រឹមត្រូវ អាចបង្ខំឱ្យអ្នករាជការនោះនៅទំនេរគ្មានបៀវត្ស ឬត្រូវផ្អាកបៀវត្ស។អ្នករាជការនោះអាចនឹងត្រូវទទួលទណ្ឌកម្មខាងវិន័យដូចមានចែងក្នុងមាត្រា ៤០ នៃច្បាប់នេះ ។

**មាត្រា៣៥ -**

ត្រូវហាមឃាត់ជាដាច់ខាត ដល់អ្នករាជការនូវប្រការខាងក្រោម ÷

១_យកម៉ោងរដ្ឋបាលទៅប្រកបមុខរបរផ្ទាល់ខ្លួនផ្សេងៗទៀត។

២_យកឥទ្ធិពលនិងអំណាចនៅក្នុងមុខងាររបស់ខ្លួនទៅប្រើ ដើម្បីទាញយកផលប្រយោជន៍អ្វីមួយឬដើម្បីសំឡុត គំរាមកំហែង បំពានសិទ្ធិរបស់ពលរដ្ឋ។

៣_ប្រកបមុខរបរណាដែលនាំឱ្យប៉ះពាល់ដល់កិត្តិយស និងសេចក្ដីថ្លៃថ្នូរនៃអ្នករាជការ។

៤_ចូលជាសមាជិកក្នុងក្រុមប្រឹក្សាភិបាល ឬគ្រប់គ្រងក្រុមហ៊ុនឯកជនដោយផ្ទាល់ឬដោយប្រយោល ។

៥_បោះពុម្ពផ្សាយ ឬធ្វើការផ្សព្វផ្សាយព័ត៌មានដែលមានពាក់ព័ន្ធនៅក្នុងមុខងារក្រសួង ដោយពុំមានការអនុញ្ញាតជាមុនពី ប្រធានស្ថាប័នដែលសាមីខ្លួននៅក្រោមឱវាទ ។

៦_ប្រកបមុខរបរបន្ថែមត្រួតលើមុខងាររបស់ខ្លួនជាអ្នករាជការ ក្នុងករណីដែលបេក្ខភាពដោយឡែកនៃអង្គនីមួយៗ ហាមឃាត់ ។

អំពើបំពាននឹងបទបញ្ញត្តិនៃមាត្រានេះអាចបណ្ដាលអោយទទួលទណ្ឌកម្មផ្នែកវិន័យណាមួយដែលមានចែងក្នុងមាត្រា ៤០ នៃច្បាប់នេះ ដោយមិនទាន់គិតដល់ការចោទប្រកាន់ជាបទអាជ្ញាដែលអាចកើតមានឡើងទៀតផង ។

**មាត្រា ៣៦ .-**

អ្នករាជការទាំងឡាយមានសិទ្ធិចូលជាសមាជិក ឬចូលរួមក្នុងការគ្រប់គ្រងសមាគមស្របច្បាប់ ។

**មាត្រា ៣៧ .-**

មន្ត្រី រាជការត្រូវមានអព្យាក្រឹត្យភាពក្នុងសកម្មភាពការងារ និងហាមឃាត់ដាច់ខាតនូវការ ប្រើប្រាស់មុខងាររបស់ខ្លួន និងសម្ភារៈរបស់រដ្ឋដើម្បីបំរើសកម្មភាពនយោបាយដូចខាងក្រោម ÷

១_ធ្វើការដើម្បីផលប្រយោជន៍ដល់បេក្ខជននយោបាយ ឬប្រឆាំងនឹងបេក្ខជននយោបាយណាមួយ ។

២_ធ្វើការដើម្បីផលប្រយោជន៍គណបក្សនយោបាយ ឬប្រឆាំងនឹងគណបក្សនយោបាយណាមួយ ។

ការប្រព្រឹត្តផ្ទុយនឹងមាត្រានេះចាត់ទុកជាកំហុសនិងការឆ្គាំឆ្គងក្នុងវិជ្ជាជីវៈ ។

**មាត្រា ៣៨ .-**

អ្នករាជការទាំងអស់ត្រូវបង្ហាញអោយឃើញថា ខ្លួនមានសមត្ថភាព ក្នុងវិជ្ជាជីវៈជាជរាបក្នុងការប្រតិបត្តិមុខងាររបស់ខ្លួន ។ អ្នករាជការទាំងអស់ត្រូវទទួលខុសត្រូវពីកំហុស និងការឆ្គាំឆ្គងក្នុងវិជ្ជាជីវៈព្រមទាំងបទល្មើសដែលខ្លួនបានប្រព្រឹត្ត ក្នុងមុខងាររបស់ខ្លួន ។

**មាត្រា ៣៩ .-**

កំហុសនិងការឆ្គាំឆ្គងក្នុងវិជ្ជាជីវៈ ត្រូវយកទណ្ឌកម្មខាងវិន័យទៅអនុវត្ត ។ ការខ្វះខាត ឬ បាត់បង់សម្បទាវិជ្ជាជីវៈអាចត្រូវដាក់អោយចូលនិវត្តន៍ បើសាមីខ្លួនបំពេញលក្ខខ័ណ្ឌដើម្បីទទួលប្រាក់សោធននិវត្តន៍ ឬបញ្ឈប់ពីការងាររាជការ ក្នុងករណីមិនគ្រប់លក្ខខ័ណ្ឌដើម្បីទទួលប្រាក់សោធននិវត្តន៍ ។

**មាត្រា ៤០ .-**

ទណ្ឌកម្មខាងវិន័យមានដូចតទៅ ÷

**១.ទណ្ឌកម្មថ្នាក់ទី ១**

ក_ស្តីបន្ទោស

ខ_ស្តីបន្ទោសដោយមានចំណារក្នុងសំណុំលិខិតផ្ទាល់ខ្លួន

គ_ផ្លាស់ដោយបង្ខំតាមវិធានការខាងវិន័យ

ឃ_លុបឈ្មោះចេញពីតារាងឡើងឋានន្តរស័ក្តិ ឬថ្នាក់

**២.ទណ្ឌកម្មថ្នាក់ទី ២**

ក_ស្តីបន្ទោសជាទម្ងន់បណ្តាលអោយលុបចេញពីតារាងឡើងឋានន្តរស័ក្តិ ឬថ្នាក់បើសិនជាមានចុះឈ្មោះហើយ ឬធ្វើអោយយឺតក្នុងការតម្លើងឋានន្តរស័ក្តិ ឬថ្នាក់ក្នុងថេរៈវេលាមួយ មានកំណត់ តែមិនត្រូវអោយលើសពី ២ ឆ្នាំ ក្នុងការ តម្លើងឋានន្តរស័ក្តិឬថ្នាក់តាមវេនជ្រើសរើស ឬតាមវេនអតីតភាព ។

ខ_ដាក់អោយនៅទំនេរគ្មានបៀវត្សមិនអោយលើសពីមួយឆ្នាំ ។

គ-បន្ថយឋានន្តរស័ក្តិឬថ្នាក់មួយថ្នាក់ ឬច្រើនថ្នាក់ ។

ឃ-ដាក់អោយចូលនិវត្តន៍មុនកំណត់ ឬបញ្ឈប់ពីការងារដោយបង្ខំ ។

ង-បណ្តេញចេញពីមុខតំណែងរាជការ ។

**មាត្រា ៤១.-**

ការស្តីបន្ទោសត្រូវធ្វើជាលិខិតផ្ញើទៅសាមីខ្លួន ដោយប្រធានអង្គភាព ឬប្រធានស្ថាប័ន ។

ការស្តីបន្ទោសដែលមានចំណារក្នុងសំណុំលិខិតផ្ទាល់ខ្លួន ការផ្លាស់ដោយបង្ខំតាមវិធានការខាងវិន័យនិងការលុប ឈ្មោះចេញពីតារាងតម្លើងឋានន្តរស័ក្តិឬថ្នាក់ ត្រូវសំរេចតាមព្រះរាជក្រឹត្យ អនុក្រឹត្យ ឬប្រកាសតាមសេចក្តីរាយការណ៍ពី ប្រធានអង្គភាព និងក្រោយពីសាមីខ្លួនបានដោះសា ។

**មាត្រា ៤២.-**

រាល់ទណ្ឌកម្មខាងវិន័យថ្នាក់ទី ២ ត្រូវសំរេចតាមព្រះរាជក្រឹត្យ អនុក្រឹត្យ ឬប្រកាសក្រោយពីមានយោបល់របស់ក្រុម ប្រឹក្សាវិន័យ ។

**មាត្រា ៤៣.-**

អ្នករាជការដែលត្រូវបន្ថយថ្នាក់ ឬឋានន្តរស័ក្តិ ត្រូវបញ្ចូលទៅក្នុងថ្នាក់ថ្មីឬឋានន្តរស័ក្តិថ្មី ចាប់គិតពីថ្ងៃដែលមានសេចក្តីសំរេចជាផ្លូវការ ។

**មាត្រា ៤៤.-**

ការបណ្តេញមន្ត្រី រាជការចេញពីមុខតំណែងគឺការដកមុខងារឬអំណាច និងឋានន្តរដែលបានប្រគល់អោយពីមុនដល់មន្ត្រី រាជការនោះ ។ ក្នុងករណីដែលត្រូវលុបចោលនូវសិទ្ធិទទួលប្រាក់សោធននិវត្តន៍ ឬប្រាក់ដែលកាត់ទុកក្នុង បេឡាសោធននិវត្តន៍ នោះត្រូវមានសេចក្តីសំរេចជាលាយល័ក្ខណ៍អក្សរ ។

**មាត្រា ៤៥.-**

ការចោទប្រកាន់អំពីកំហុសខាងវិន័យត្រូវធ្វើដោយសេចក្តីសំរេចរបស់ថ្នាក់គ្រប់គ្រង ដែលមានសមត្ថកិច្ច ក្រោយពីមានសេចក្តីរាយការណ៍ពិស្តារពីប្រធានអង្គភាពឬប្រធានស្ថាប័ន ។

**មាត្រា ៤៦.-**

អនុក្រឹត្យឬប្រកាសដែលសំរេចចោទប្រកាន់អំពីកំហុសខាងវិន័យនាំអោយមានការផ្អាកមុខងារនៃអ្នករាជការនោះ ជាបណ្តោះអាសន្ន តែមិនមានការបន្ថយបៀវត្សទេ ។ ក្នុងរយៈពេលមួយខែយ៉ាងយូរ ក្រុមប្រឹក្សាវិន័យត្រូវកោះប្រជុំដើម្បីផ្តល់ យោបល់ ។

សេចក្តីសំរេចផ្អាកការងារអ្នករាជការអោយឈប់ពីតំណែងមានកំណត់ត្រឹម៣ខែ ប៉ុន្តែបើជាករណីពិសេសអាចសំរេចអោយបន្តជាថ្មីទៀតបាន កំណត់ ០១ ខែម្តង ប៉ុន្តែការបន្តនោះមិនត្រូវលើសពី៣ដងឡើយ ។

**មាត្រា ៤៧ ..**

ការចោទប្រកាន់អំពីកំហុសខាងវិន័យ ត្រូវធ្វើការអង្កេតជាមុនសិនចំពោះទណ្ឌកម្មខាងវិន័យថ្នាក់ទី២។ ការអង្កេតត្រូវប្រគល់អោយតំណាងប្រធានស្ថាប័នសាមីមួយរូបឬច្រើនរូប ដែលមានឋានន្តរស័ក្តិ និងថ្នាក់ខ្ពស់ជាង ឬអតីតភាពច្រើនជាងអ្នករាជការដែលត្រូវជាប់ចោទ ។

សំណុំរឿងអង្កេតត្រូវបញ្ជូនទៅប្រធានស្ថាប័នដើម្បីពិនិត្យ និងសំរេចថាគួរបញ្ជូនអ្នករាជការជាប់ចោទនោះទៅអោយក្រុមប្រឹក្សាវិន័យ ឬក៏សំរេចថាគួរបញ្ឈប់ការចោទប្រកាន់វិញ ។ ក្នុងករណីដែលប្រធានស្ថាប័នយល់ថាគួរបន្តការ ចោទប្រកាន់ សំណុំរឿងត្រូវបញ្ជូនទៅក្រុមប្រឹក្សាវិន័យដែលត្រូវអញ្ជើញអ្នករាជការជាប់ចោទមកពន្យល់ដោះសារដោយផ្ទាល់មាត់ និងជាលាយលក្ខណ៍អក្សរមុននិងក្រុមប្រឹក្សាវិន័យធ្វើការសន្និដ្ឋានអំពីកំហុសនិងទណ្ឌកម្ម ដើម្បីជាយោបល់ ដល់ថ្នាក់មានសមត្ថកិច្ចសំរេច ។

**មាត្រា ៤៨ ..**

ក្រុមប្រឹក្សាវិន័យ ត្រូវមានសមាជិក ៥ នាក់ ៖

- អ្នករាជការ ៣ នាក់ ចាត់តាំងដោយប្រធានស្ថាប័ន ដែលអ្នករាជការជាប់ចោទនោះនៅក្រោមឱវាទ ម្នាក់បំពេញមុខងារជាប្រធាន និងម្នាក់ទៀតបំពេញមុខងារជាអ្នកធ្វើរបាយការណ៍ ។
- អ្នករាជការ ២ នាក់ ដែលនៅក្នុងក្របខ័ណ្ឌជាមួយគ្នានឹងអ្នករាជការជាប់ចោទ ប៉ុន្តែមានឋានន្តរស័ក្តិខ្ពស់ជាង ឬមានអតីតភាពការងារចាស់ជាងក្នុងថ្នាក់ស្មើគ្នា ។ មិនអាចចាត់តាំងអោយចូលក្នុងក្រុមប្រឹក្សាវិន័យនេះបាន អ្នករាជការណាដែលជាអ្នកធ្វើពាក្យបណ្តឹងចំពោះអ្នករាជការជាប់ចោទ ឬជាក្រុមញាតិរហូតដល់ជួរទី ៣ របស់អ្នករាជការជាប់ចោទ នោះ ។

**មាត្រា ៤៩ ..**

អ្នកធ្វើរបាយការណ៍មានភារកិច្ចត្រូវជំរាបទៅអ្នករាជការជាប់ចោទនូវសិទ្ធិរបស់អ្នករាជការនោះដូចតទៅ :

១. សិទ្ធិសុំមើលសំណុំរឿងផ្ទាល់ខ្លួន

២. សិទ្ធិសុំអាងសាក្សី

៣. សិទ្ធិជ្រើសរើសតំណាងការពារខ្លួន

៤_សិទ្ធិពន្យល់ដោះសាជាលាយលក្ខណ៍អក្សរ ឬដោយផ្ទាល់មាត់ ។

**មាត្រា ៥០ ..**

ក្រោយពេលបានទទួលរបាយការណ៍ ក្រុមប្រឹក្សាវិន័យអាចបង្គាប់អោយអ្នកធ្វើរបាយការណ៍រកពត៌មានបន្ថែមទៀតបាន ។

ប្រធានអាចពន្យាពេលប្រជុំក្រុមប្រឹក្សាវិន័យទៅថ្ងៃក្រោយបាន ព្រមទាំងអាចចាត់វិធានការផ្សេងៗដែលមានសារ ប្រយោជន៍ដើម្បីរកការពិត និងកុំអោយប៉ះពាល់ដល់សេចក្តីវិនិច្ឆ័យរបស់តុលាការ ក្នុងករណីដែលតុលាការបានសំរេចជា មុនមកហើយ ។

នីតិវិធីនៃការអនុវត្តវិន័យនឹងត្រូវកំណត់ដោយអនុក្រឹត្យ ។

## ជំពូកទី ៦
## ការចោទប្រកាន់តាមផ្លូវតុលាការ

**មាត្រា ៥១ ..**

អ្នករាជការដែលជាប់បណ្តឹងពីបទមជ្ឈិមឬបទឧក្រិដ្ឋចំពោះមុខតុលាការ អាចត្រូវចោទប្រកាន់បានលុះត្រាមានសេចក្តីអនុញ្ញាតបើកអោយចោទប្រកាន់ជាមុនពីគណៈរដ្ឋមន្ត្រី តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ចំពោះមន្ត្រីដែល មានបៀវត្សស្មើឬលើសបៀវត្សឧត្តមមន្ត្រីថ្នាក់លេខ ៣ ឬមានឋានៈជាប្រតិភូរាជរដ្ឋាភិបាលប្រចាំរាជធានីនិងក្រុង អភិបាលខេត្ត ក្រុង ។ ចំពោះអ្នករាជការដែលមានបៀវត្សទាបជាងបៀវត្ស ឧត្តមមន្ត្រីថ្នាក់លេខ ៣ វិញ សេចក្តីអនុញ្ញាតជា មុនអោយចោទប្រកាន់នោះត្រូវសំរេចត្រឹមប្រធានស្ថាប័នសាមី ។

ក្នុងករណីបទល្មើសជាក់ស្តែង តុលាការអាចបង្គាប់អោយឃុំខ្លួនភ្លាមមិនចាំបាច់មានសេចក្តី អនុញ្ញាតអោយចោទប្រកាន់ទេ ប៉ុន្តែត្រូវជូនដំណឹងអំពីរឿងនេះជាប្រញាប់ទៅប្រធានស្ថាប័នសាមី ។

**មាត្រា ៥២ ..**

អ្នករាជការណាដែលកំពុងជាប់ការចោទប្រកាន់ទៅតុលាការជំនុំជំរះ អាចត្រូវបានផ្អាកពីមុខងារសិនក្នុងករណីចាំ បាច់ ។

ក្នុងករណីដែលអ្នករាជការត្រូវផ្អាកពីការងារដោយផ្អាកបៀវត្ស អ្នករាជការនោះត្រូវបានទទួលអោយចូលធ្វើការវិញ ព្រមដោយគិតពីអតីតកាល ឋានន្តរស័ក្តិ សោធននិវត្តន៍ និងទទួលបៀវត្សប្រតិសកម្មផងបើតុលាការប្រកាសអោយរួចខ្លួនជា ស្ថាពរ ។

**មាត្រា ៥៣ ..**

ការផ្តន្ទាទោសជាបទឧក្រិដ្ឋ ឬជាបទមជ្ឈិមដោយឥតព្យួរទោស បណ្តាលអោយមានការហូតងារ អ្នករាជការនោះ គិត ពីថ្ងៃសាលក្រមចូលជាស្ថាពរ ។

អ្នករាជការដែលតវ៉ាសុំឧទរណ៍ត្រូវដាក់អោយនៅទំនេរគ្មានបៀវត្សជាបណ្តោះអាសន្នដោយស្វ័យប្រវត្តិ ។

# ជំពូកទី ៧

## ការចូលនិវត្តន៍

**មាត្រា ៥៤ ..**

អ្នករាជការទាំងពីរភេទត្រូវដាក់អោយចូលនិវត្តន៍ជាកំហិត ពេលដល់អាយុ ៥៥ ឆ្នាំ ។ អាយុកំហិតនេះអាចរំកិលឡើងដល់ ៦០ ឆ្នាំបើលក្ខន្តិកៈដោយឡែកបានកំណត់ ។ ដើម្បីមានសិទ្ធិទទួលសោធននិវត្តន៍អតីតភាពបាន អ្នករាជការត្រូវបំពេញលក្ខខ័ណ្ឌដូចតទៅ ÷

_មានអាយុ ៥៥ ឆ្នាំ

_មានអតីតភាពការងារ ៣០ ឆ្នាំ

ប៉ុន្តែអ្នករាជការដែលបានបំរើការងារអស់រយៈពេល ៣០ ឆ្នាំហើយ អាចសុំចូលនិវត្តន៍មុនអាយុ ៥៥ ឆ្នាំបានដោយ ទទួលប្រាក់សោធននិវត្តន៍អតីតភាព ។

**មាត្រា៥៥ ..**

អ្នករាជការដែលបំពេញការងារបាន៣០ឆ្នាំយ៉ាងតិចត្រូវទទួលប្រាក់សោធននិវត្តន៍អតីតភាព។

អ្នករាជការដែលបានបំពេញការងារក្រោម ២០ឆ្នាំ ត្រូវទទួលប្រាក់សោធននិវត្តន៍ដែលបានកាត់ទុក និងប្រាក់ឧបត្ថម្ភផ្សេងៗរបស់រដ្ឋតែមួយលើក។

អ្នករាជការដែលបំពេញការងារក្នុងចន្លោះរយៈពេលពី២០ឆ្នាំដល់ក្រោម៣០ឆ្នាំត្រូវបានទទួលប្រាក់សោធននិវត្តន៍សមាមាត្រ។

**មាត្រា៥៦ ..**

ក្នុងរយៈពេលបន្តការងារក្រោយពេលដល់អាយុចូលនិវត្តន៍ ចំពោះអ្នករាជការដែលមានអតីតភាពគ្រប់៣០ឆ្នាំហើយ មិនត្រូវកាត់ទុកប្រាក់សោធននិវត្តន៍ឡើយ ប៉ុន្តែបើអតីតភាពការងារមិន ទាន់ គ្រប់ ៣០ ឆ្នាំ

នោះត្រូវ កាត់ទុកប្រាក់សោធននិវត្តន៍ ហើយរាប់បញ្ចូលចំនួនឆ្នាំដែលបានបន្តការងារ ដើម្បីទទួលប្រាក់សោធននិវត្តន៍ ។

**មាត្រា ៥៧ .-**

អតីតភាពការងាររបស់អ្នករាជការត្រូវគិតតាំងពីថ្ងៃដែលសាមីខ្លួនបានចូលបំរើការងាររដ្ឋទោះក្នុងសម័យណាក៏ដោយ ។

## ជំពូកទី ៨

## ការដោះស្រាយជំនាស់ពាក់ព័ន្ធនឹងកិច្ចការមុខងារសាធារណៈ

**មាត្រា ៥៨ .-**

អ្នករាជការមានសិទ្ធិប្តឹងតវ៉ាទៅតុលាការ អំពីករណីដែលពាក់ព័ន្ធទៅនឹងកិច្ចការមុខងារសាធារណៈ ។ ប៉ុន្តែជាការចាំបាច់ អ្នករាជការនោះត្រូវរកវិធីដោះស្រាយតាមផ្លូវរដ្ឋបាលជាមុនសិន ។

**មាត្រា ៥៩ .-**

សមត្ថកិច្ចដើម្បីដោះស្រាយទំនាស់ខាងលើនេះ ត្រូវប្រគល់ជូនគណៈកម្មាធិការអចិន្ត្រៃយ៍មួយមានឈ្មោះថា គណៈកម្មាធិការសំរុះសំរួលទំនាស់ពាក់ព័ន្ធនឹងកិច្ចការមុខងារសាធារណៈ ដែលមានប្រធានស្ថាប័នមុខងារសាធារណៈជាប្រធាន ហើយនឹងមានសមាសភាពដែលកំណត់ដោយអនុក្រឹត្យ ។

## ជំពូកទី ៩

## បទបញ្ញត្តិដោយឡែក

**មាត្រា ៦០ .-**

ការកែសំរួលចំនួនអ្នករាជការតាមសភាពជាក់ស្តែងជាសមត្ថកិច្ចរបស់រាជរដ្ឋាភិបាល ។ ក្នុងករណីដែលត្រូវកាត់បន្ថយចំនួនអ្នករាជការជាការចាំបាច់ ជាគោលការណ៍ ការរំសាយត្រូវប៉ះពាល់ជាបឋមចំពោះអ្នករាជការដែលជិតដល់អាយុចូលនិវត្តន៍ ដែលមានសម្បទាវិជ្ជាជីវៈថមថយ និងអ្នកដែលស្ម័គ្រចិត្តឈប់ពីការងារ ។

**មាត្រា ៦១ .-**

ជាគោលការណ៍ អ្នករាជការក្របខ័ណ្ឌមានអាទិភាពក្នុងការទទួលមុខតំណែងណាមួយ ។ តែក្នុងករណីពិសេស ផ្អែកលើការចាំបាច់ រាជរដ្ឋាភិបាលអាចតែងតាំងវរជនណាម្នាក់ ឬជនដែលមានសញ្ញាប័ត្រខ្ពស់ អោយកាន់មុខតំណែងអ្វីមួយក៏ បាន ទោះវរៈជនឬជននោះពុំមែនជាមន្ត្រីក្របខ័ណ្ឌក៏ដោយ ។

ក្នុងលក្ខណៈនេះ សាមីខ្លួនមានសិទ្ធិទទួលបៀវត្សជាធម្មតា តែគ្មានសិទ្ធិទទួលសោធននិវត្តន៍ទេ ។

**មាត្រា ៦២.-**

រាជរដ្ឋាភិបាលអាចតែងតាំងអោយចូលក្របខ័ណ្ឌអ្នករាជការនៅពេលណាក៏បាន ចំពោះវរៈជន ឬជន ដែលមានសញ្ញាប័ត្រខ្ពស់ ដែលមានផលប្រយោជន៍ដល់ការងាររដ្ឋ ដោយមិនគិតពីលក្ខខ័ណ្ឌអាយុ ។

# ជំពូកទី ១០

## អន្តរប្បញ្ញត្តិ

**មាត្រា ៦៣ .-**

ចាប់តាំងពីច្បាប់នេះចូលជាធរមាន រហូតដល់ឆ្នាំ ២០០០ អ្នករាជការដែលមានអាយុលើសពី ៥៥ ឆ្នាំ អាចអនុញ្ញាតបន្តអោយធ្វើការងារបាន តាមការស្នើសុំរបស់សាមីខ្លួន និងតាមការសំរេចដោយអនុក្រឹត្យផ្អែកលើ យោបល់ឯកភាព ពីស្ថាប័ន មុខងារសាធារណៈ និងប្រធានស្ថាប័នសាមី ។ ការបន្តនេះមានរយៈពេលមួយឆ្នាំម្តងៗ តែមិនអោយលើសពី ៥ ឆ្នាំទេ ។

# ជំពូកទី ១១

## អវសានប្បញ្ញត្តិ

**មាត្រា ៦៤ .-**

បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយពីច្បាប់នេះត្រូវទុកជានិរាករណ៍ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ១៩៩៤

ក្នុងព្រះបរមនាមនិងតាមព្រះរាជបង្គាប់

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា

**ជា ស៊ីម**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

នាយករដ្ឋមន្ត្រីទី ១ នាយករដ្ឋមន្ត្រីទី ២

ព្រះហស្តលេខា និង ហត្ថលេខា

**នរោត្តម រណឫទ្ធិ** **ហ៊ុន សែន**

បានបង្គំទូលថ្វាយ និង ជំរាបជូន

សម្តេចនាយករដ្ឋមន្ត្រីទី ១ និងទី ២

សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

ហត្ថលេខា

**សុខ អាន** **វេង សិរីវុឌ្ឍ**